**បទប៉ុនប៉ង (Attempt)**

១. ដំណើរការឈានទៅសម្រេចបទល្មើសព្រហ្មទណ្ឌ មាន ៦ ដំណាក់កាលៈ ការគិត វាយតម្លៃ បង្កើតចេតនា (forming intent ) រៀបចំ ចាប់ផ្តើម និង លទ្ធផល។ ជាទូទៅ បីដំណាក់កាលដំបូង នឹងមិនទាន់នាំឲ្យទទួលខុសត្រូវទេ។ ការប្រព្រឹត្ត មិនបានសម្រេច ត្រូវបានចាត់ជាសាមញ្ញ ថាជាការប៉ុនប៉ង។

២. គ្រប់បទឧក្រិដ្ឋទាំងអស់ សុទ្ធតែអាចជាការប៉ុនប៉ង។ រីឯបទមជ្ឈិម អាចជាបទប៉ុនប៉ង លុះត្រាមានច្បាប់ចែងកំណត់ជាក់លាក់។ នេះ ទំនងជាឲ្យស្រប នឹង គោលការណ៍នីត្យានុកូលភាព http://www.measboralaws.com/detail/738។ បទលហុ (infraction) គ្មានការប៉ុនប៉ងទេ។ បទប៉ុនប៉ងជាប្រភេទបទល្មើស ទាមទារចេតនាជាក់លាក់ http://www.measboralaws.com/detail/1060 និងមានចេតនាត្រួត (double intent) ក្នុងន័យថា ជនល្មើសមានចេតនាចង់បានអ្វីមួយជាក់លាក់ ហើយចេតនាប្រព្រឹត្តឲ្យបានសម្រេច ក៏ប៉ុន្តែត្រូវបានខកខាន។

៣. ប៉ុនប៉ង ត្រូវបានចែកជាពីរប្រភេទៈ ១. សម្រេច (complete attempt) និង មិនសម្រេច (incomplete)។ ទី១ សំដៅការបញ្ចប់សកម្មភាពរួចហើយ តែមិនបានបំពេញគោលដៅ ដូចជា បាញ់ជនរងគ្រោះខុស។ ទីពីរ ហៀបនឹងបាញ់ តែអាក់ខានដោយសារកត្តាខាងក្រៅ ដូចជា ប៉ូលីសចាប់ខ្លួនជនល្មើស។ ជារួម ការចាត់ថាជាការប៉ុនប៉ង គឺជាការខកខានមិនបានបំពេញតាមបំណង នៃបទល្មើស ដែលជនល្មើសប៉ងប្រាថ្នា។ ជនល្មើសបាន ឆ្លងកាត់ដំណាក់កាល ត្រៀមប្រព្រឹត្តិរួចហើយ (pass preparation phase)។ វាមានការពិបាកក្នុងការសន្និដ្ឋាន ថាអ្វីទៅជាដំណាក់កាលនៃការរៀបចំ។ យុត្តាធិការ របស់រដ្ឋ បានប្រើនូវស្តង់ដាផ្សេងៗ ដើម្បីកំណត់។

៤. ទី១. សកម្មភាពនៅកៀកកិតនឹងការសម្រេច (proximate test)៖ ជនល្មើសរៀបនឹងកាច់កៃកាំភ្លើងបាញ់ ឬ ចាប់ផ្តើមកេះដែកកេស (បទបង្កអគ្គិភ័យ) ឬ ផ្តួលជនរងគ្រោះលើដី ហែកសំលៀកបំពាក់ (បទរំលោភសេពសន្ថវៈ)។ ក្នុងន័យនេះ ការណ៍ដែលប៉ូលសីឃាត់ម៉ូតូ ជនសង្ស័យនៅទីតាំងមួយ ឃើញមានសម្ភារៈ ដែលអាចយកទៅប្រព្រឹត្តបទល្មើស ហើយចោទថាប៉ុនប៉ងប្រព្រឹត្តិនៅទីតាំងផ្សេងមួយ ដ៏ឆ្ងាយ ទំនងជាមិនសមហេតុផលទេ ដោយសារ លើដំណើរផ្លូវវែងឆ្ងាយ ជនល្មើសអាចប្តូរចិត្ត មិនប្រព្រឹត្តបទល្មើស។ ទី២. បំពេញនូវដំណាក់កាលសំខាន់ នៃការប្រព្រឹត្តបទល្មើស (Substantial step)៖ ឧទាហរណ៍ អាចស្រដៀងនឹងការរៀបបាញ់កាំភ្លើង។ ក៏ប៉ុន្តែអ្វីដែលខុសពី proximate test គឺកត្តាពេល

វេលា។ ទី៣. សកម្មភាពជាក់លាក់របស់ជនល្មើស (clear act test)៖ តុលាការនឹងមើលជាសំខាន់សកម្មភាពរួមរបស់ជនល្មើស ដើម្បីពិនិត្យមើលចេតនា។

៥. ក្នុងពេលប្រព្រឹត្ត ហេតុការណ៍អាចកើតមានឡើង ដូចជា ជនល្មើសលួចយកកាបូប ដើម្បីបានលុយ តែកាបូបបែរជាគ្មានលុយ បាញ់សម្លាប់មនុស្ស តែមនុស្សបានស្លាប់បាត់ទៅហើយ។ នេះ ជាភាពមិនអាចកើតមាន (impossibility) ដែលចែកចេញជាពីរ គឺតាមផ្លូវច្បាប់ (legal impossibility: LI) និងអង្គហេតុ (factual impossibility) ដែលខាងក្រោយនេះ ចែកចេញជាពីរគឺធម្មតា និង មានភ្ជាប់មកជាមួយ (inherent factual impossibility)។  ការចូលទៅកាន់កាប់ដីអនុញ្ញាតដោយច្បាប់ តែជនល្មើសយល់ថាដីនោះ មិនអាចត្រូវអនុញ្ញាតឲ្យកាន់កាប់។ នេះ ជា LI។ ការបាញ់កាំភ្លើង តែបែរជាមិនចេញដោយសារគ្រាប់ស្អុយ។ នេះជា Inherent factual impossibility ផ្ទុយពីការបាញ់កាំភ្លើងចេញ តែខុសមនុស្សមុខសញ្ញា (normal factual impossibility)។

៦. យុត្តាធិការជាច្រើន ចាត់ទុក LI ជាការដោះសារឲ្យរួចផុតពីការទទួលខុសត្រូវ ដោយសារសកម្មភាពនោះ មិនខុសច្បាប់ (សូមមើលឧទាហរណ៍ខាងលើ)។ ជាចុងក្រោយ ជនល្មើសក៏អាចនឹងរួចផុតពីការទទួលខុសត្រូវផងដែរ ប្រសិន បើគាត់បានបញ្ឈប់ទាំងស្រុង ដោយស្ម័គ្រចិត្តចេញពីឆន្ទៈរបស់ខ្លួន ( complete and voluntary)។ នេះក្នុងន័យថា ប៉ុនប៉ងរំលោភស្ត្រីម្នាក់មិនបាន ចង់រំលោភស្ត្រីផ្សេងទៀត (not complete)។ ស្ម័គ្រចិត្ត សំដៅកើតចេញពីក្នុងចិត្ត មិនមែនមានឥទ្ធិពលដោយសារកត្តាខាងក្រៅទេ។ នេះទំនងជាកើតឡើងមុនការប្រព្រឹត្ត substantial act។ ឧទាហរណ៍ ក្នុងបទរំលោភសេពសន្ថវៈ នារីរងគ្រោះកំពុងដើរមក ខណៈដែលជនល្មើស កំពុងរង់ចាំ។ នាពេលនោះ គាត់ពិចារណាថា ជាទង្វើ ខុសច្បាប់ គាត់ក៏បញ្ឈប់ រួចដើរគេចចេញទៅ។ ផ្ទុយទៅវិញ ប្រសិនបើ គាត់ចាប់ផ្ដើមស្ទាបអង្អែលនាងដោយបង្ខំហើយ គាត់បានបញ្ឈប់ ដោយសារការអង្វររបស់នារីរងគ្រោះ វានៅតែជាបទប៉ុនប៉ង (incomplete attempt)។ ផ្សេងពីនេះ បើបុរសនោះចាប់ផ្ដើមប្រព្រឹត្ត ផ្ដួល ហែក អាវ និងដោះខោរបស់ខ្លួន ហើយប៉ូលីសមកដល់ នេះគឺជាការប៉ុនប៉ុងសេពសន្ថវៈបានសម្រេច (complete attempt)។ ដើម្បី ជ្រាបច្បាស់ សូមពិនិត្យមើលលក្ខន្តិកៈទីក្រុងរ៉ូម មាត្រា ២៥(៣) ដែលចែងថា៖ *ទទួលខុសត្រូវនូវការប៉ុនប៉ងប្រព្រឹត្ត ដោយធ្វើសកម្មភាពដែលចាប់ផ្ដើមប្រព្រឹត្ត ដោយមធ្យោបាយចម្បង (substantial step) ក៏ប៉ុន្តែ បទល្មើសមិនបានកើតមានដោយសារស្ថានភាព ឯករាជក្រៅចេតនារបស់ជនល្មើស។... ក៏ប៉ុន្តែ ជនល្មើសដែលបោះបង់ការខិតខំ ប្រព្រឹត្តបទល្មើស ឬ ផ្សេងពីនេះ រារាំងនូវការសម្រេចបទល្មើស នឹងមិន*

*ទទួលខុសត្រូវនូវទោសទណ្ឌ...សម្រាប់ការប៉ុនប៉ងក្នុងការប្រព្រឹត្តបទល្មើសទេ ប្រសិនបើបុគ្គលនោះ បានបោះបង់ដោយស្ម័គ្រចិត្ត និងទាំងស្រុងនូវគោលបំណងព្រហ្មទណ្ឌ។*

**៧**. យុត្តាធិការភាគច្រើន ផ្តល់ទោសទណ្ឌដល់បទប៉ុនប៉ង ស្រាលជាងបទល្មើសបានសម្រេច។

**<u>កំណត់សំគាល់</u>**៖មាត្រា ២៧ នៃក្រមព្រហ្មទណ្ឌឆ្នាំ ២០០៩ នៃកម្ពុជាចែង៖ "*ការប៉ុនប៉ងក្នុងបទឧក្រិដ្ឋ ឬក្នុងករណីដែលច្បាប់បានចែងទុកក្នុងបទមជ្ឈិម អាចត្រូវបានផ្តន្ទាទោសបាន កាលណាលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ៖ - ចារីបាន<u>ចាប់ផ្តើមអនុវត្ត</u>បទល្មើស មានន័យថា ចារីបានប្រព្រឹត្ត អំពើដែល<u>មានគោលបំណងដោយផ្ទាល់ដើម្បី</u>ប្រព្រឹត្តបទល្មើស និង -ចារីមិនបានបញ្ឈប់អំពើរបស់ខ្លួនទៅវិញដោយស្ម័គ្រចិត្ត តែត្រូវបានរាំងស្ទះ ឬអាក់ខាន ដោយឥទ្ធិពលនៃកាលៈទេសៈ<u>ក្រៅឆន្ទៈរបស់ខ្លួ</u>ន។ អំពើត្រៀមបម្រុង ដែលពុំមានគោលបំណងដោយផ្ទាល់ ដើម្បីប្រព្រឹត្តបទល្មើស មិនមែនជាការចាប់ផ្តើម ទេ។ ការប៉ុនប៉ងបទលហុពុំទទួលការផ្តន្ទាទោសទេ។*"

**ឯកសារយោង៖** **1**. Catherine Elliott, French Criminal Law, 2001, pp.95-100; **2**. Jens Ohlin, *Inchoate Crime* in Antonio Cassese, the Oxford Companion to the International Criminal Justice, 2009, pp. 372-373; **3**. Michael Bohlander, Principle of German Criminal Law, 2009, pp.137-152; **4**. Kevin Jon Heller and Markus D. Dbber, the Handbook of Comparative Criminal Law, 2011, pp. 110, 220, 263; **5**. Vivenne O'Connor and Colette Rausch, Model Codes for Post-Conflict Criminal Justice, Model Criminal Code, 2007, pp. 87-88; **6.** Joshua Dressler, Understanding Criminal Law, 2009, pp. 379-419; **7**. Matthew Lippman, Contemporary Criminal Law, 2010, pp. 178-195; **8.** Alan Reed and Michael Bohlander, Participation in Crime: Domestic and Comparative Perspectives, 2013, pp. 286, 303 and 337, and **9**. Robert Cryer, *Attempt* in Dinah L. Shelton, Encyclopedia of Genocide and Crimes against Humanity, 2005, pp. 95-96.